# ឥឡូវនេះ លក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធី Medi-Cal គឺកាន់តែមានភាពងាយស្រួលជាងពេលណាណាទាំងអស់។

## ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2024 ទ្រព្យសម្បត្តិនឹងមិនត្រូវបានរាប់បញ្ចូល ដើម្បីកំណត់លក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធី Medi-Cal ទៀតឡើយ!



ការមានការថែទាំសុខភាពគឺចាំបាច់។ តាមរយៈការរ៉ាប់រងលើសេវាថែទាំផ្នែកវេជ្ជសាស្ត្រ ចក្ខុ ធ្មេញ និងសេវាថែទាំសុខភាពផ្លូវចិត្ត កម្មវិធី Medi-Cal អាចជួយឱ្យអ្នកមានសុខភាពល្អ។ ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០២៤ មនុស្សកាន់តែច្រើននាក់នឹងអាចមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធី Medi-Cal ដោយសារនៅពេលនេះ ដែនកំណត់ទ្រព្យសម្បត្តិត្រូវបានលុបចោលទាំងស្រុងពីកម្មវិធីនេះ។

**នេះមានន័យថា** អ្នកអាចរក្សាទុកប្រាក់សន្សំ និងទ្រព្យសម្បត្តិបានបន្ថែមទៀត ខណៈពេលដែលទទួលបានការរ៉ាប់រងលើការថែទាំសុខភាពសំខាន់ៗដែលអ្នកត្រូវការ តាមរយៈកម្មវិធី Medi-Cal។

សូមអានបន្ត ដើម្បីស្វែងយល់បន្ថែម ▶

Alameda County
Social Services Agency

DHCS

## តើទ្រព្យសម្បត្តិគឺជាអ្វី?

ទ្រព្យសម្បត្តិគឺជាវត្ថុដែលជាកម្មសិទ្ធិរបស់អ្នក រួមទាំងគណនីធនាគារ សាច់ប្រាក់ យានជំនិះ អចលនទ្រព្យ និងធនធានហិរញ្ញវត្ថុផ្សេងទៀត។

## តើទ្រព្យសម្បត្តិរួមបញ្ចូលចំណូលប្រចាំខែដែរឬទេ?

**ទេ** ទ្រព្យសម្បត្តិមិនរួមបញ្ចូលចំណូលប្រចាំខែពីការងារ របបសន្តិសុខសង្គម ឬប្រាក់ចូលនិវត្តន៍ទេ។

## ចុះប្រសិនបើខ្ញុំត្រូវបានគេបដិសេធមិនឱ្យទទួលបានការរ៉ាប់រងពីកម្មវិធី Medi-Cal ដោយសារតែដែនកំណត់ទ្រព្យសម្បត្តិពីអតីតកាល?

ប្រសិនបើអ្នកត្រូវបានគេរកឃើញថាមិនមានសិទ្ធិ ឬត្រូវបានគេបដិសេធមិនឱ្យទទួលបានអត្ថប្រយោជន៍ ដោយសារតែដែនកំណត់ទ្រព្យសម្បត្តិក្នុងរយៈពេល**ប្រាំមួយខែមុនថ្ងៃទី 1 ខែមករា ឆ្នាំ 2024** នោះអ្នកនឹងទទួលបានលិខិតមួយអំពីការផ្លាស់ប្តូរដែនកំណត់ទ្រព្យសម្បត្តិ ហើយនឹងទទួលបានជម្រើសក្នុងការដាក់ពាក្យសុំចូលរួមកម្មវិធី Medi-Cal ម្តងទៀត។

## តើខ្ញុំអាចដាក់ពាក្យសុំចូលរួមកម្មវិធី Medi-Cal បានដោយវិធីណា?

**HealthyAC.org**

មានអង្គការដែលមានមូលដ្ឋានក្នុងសហគមន៍ដែលនៅជិតអ្នក ដើម្បីជួយអ្នកក្នុងការដាក់ពាក្យ ហើយនឹងឆ្លើយសំណួរទាំងឡាយដែលអ្នកអាចមាន។ គ្រាន់តែចូលទៅកាន់ **HealthyAC.org** នៅថ្ងៃនេះជាការស្រេច។

**BenefitsCal**

ប្រសិនបើអ្នកចង់ អ្នកក៏អាចដាក់ពាក្យដោយខ្លួនឯងបានផងដែរ តាមរយៈ **BenefitsCal.com**។

**សូមកុំខកខានក្នុងការទទួលបានការរ៉ាប់រងការថែទាំសុខភាពដែលអ្នកត្រូវការតាមរយៈកម្មវិធី Medi-Cal។**

**សូមដាក់ពាក្យនៅថ្ងៃនេះ!**